# HIV ➢ ប្រពន្ធ័សុខភាពក្នុងប្រទេសអូស្ត្រាលី

7.1 សេចក្ដីផ្ដើម
7.2 វេជ្ជបណ្ឌិតទូទៅ
7.3 កិច្ចបំរើសុខភាពផ្នែកផ្លូវភេទ
7.4 មន្ទីរពេទ្យ
7.5 កិច្ចបំរើមេរោគ HIV និងជំងឺអេដស៍ដ៏ទៃទៀត
7.6 អ្នកផ្ដល់យោបល់និងឱវាទ សង្គមការី និងអ្នកចិត្តសាស្ត្រ
7.7 របៀបប្រើកិច្ចបំរើដែលអ្នកត្រូវការ
7.8 អ្នកបកប្រែ

## 7.1 សេចក្ដីផ្ដើម

ប្រពន្ធ័សុខភាពគឺជាពាក្យដែលមានន័យទូលាយ ប្រើសំរាប់ពត៌មានអំពីកិច្ចបំរើ អង្គការផ្សេងៗនិងបុគ្គលិកដែលកំពុងផ្ដល់នូវកិច្ចបំរើផ្នែកសុខភាពនៅក្នុងសហគមន៏ ។ ទាំងនេះរាប់បញ្ចូលទាំងវេជ្ជបណ្ឌិតទូទៅមន្ទីរពេទ្យ បុគ្គលិកសង្គមកិច្ច (social workers) អ្នកបកប្រែ (interpreters) ពេទ្យធ្មេញ និងកិច្ចបំរើផ្សេងទៀតដែលថែរក្សាសុខភាព និងផ្នែកសុខភាព ។

ការស្វែងរកពត៌មាននិងកិច្ចបំរើដែលអ្នកត្រូវការគឺជាកិច្ចការដ៏លើសលុប ជាពិសេសបើសិនជាលោកអ្នកមិនស្រួលខ្លួន ឬអ្នកចេះភាសាអង់គ្លេសមិនដល់ ។ ទោះជាយ៉ាងណាក៏ដោយ អ្នកមានមេរោគ HIV/AIDS ប្រហែលជាត្រូវការកិច្ចបំរើផ្នែកសុខភាពខ្លះ ដែលអ្នកមិនធ្លាប់ប្រើពីមុនមក ។ វាជាការសំខាន់ដែលអ្នកដឹងថាកិច្ចបំរើសុខភាពណាមួយដែលអាចផ្ដល់កិច្ចបំរើដល់អ្នក ហើយអ្នកអាចប្រើកិច្ចបំរើទាំងនោះតាមរបៀបណា ។

វេជ្ជបណ្ឌិត និងបុគ្គលិកថែរក្សាសុខភាពក្នុងសហគមន៏របស់អ្នកមានការយល់ដឹងច្រើនអំពីប្រពន្ធ័សុខភាព ។ អ្នកអាចសួរបុគ្គលិកទាំងនេះអំពីប្រពន្ធ័សុខភាព ដោយពុំចាំបាច់ប្រាប់គេថា អ្នកមានមេរោគ HIVឡើយ ។ ពួកគេអាចប្រាប់អ្នកអំពីមន្ទីរពេទ្យ មន្ទីរព្យាបាលរោគ និងកិច្ចបំរើផ្សេងទៀតដែលផ្ដល់កិច្ចបំរើ HIV នៅក្នុងតំបន់អ្នក ហើយអ្នកអាចទៅកន្លែងទាំងនេះ ដើម្បីសួររកពត៌មានបន្ថែមអំពីមេរោគ HIV ។

កិច្ចបំរើសុខភាពជាច្រើនផ្ដល់ជូនដោយឥតគិតថ្លៃបើសិនជាអ្នកមានប័ណ្ណមេឌីឃែ (Medicare Card) ។ របៀបនេះហៅថា ប៊ូលប៊ីលលីង (Bulkbilling) ។ វេជ្ជបណ្ឌិត និងមន្ទីរព្យាបាលជាច្រើន នឹងមិនគិតលុយពីអ្នកទេ បើសិនជាអ្នកបង្ហាញប័ណ្ណមេឌីឃែ (Medicare Card) របស់អ្នកទៅគេ ប៉ុន្តែអ្នកប្រហែលជាត្រូវបង់ថ្លៃថ្នាំឬក៏ថ្លៃធ្វើតេស្ត ។

បន្ថែមទៀតដែលគេបានធ្វើឱ្យអ្នក ។ សំណុំរឿងដែលទាក់ទងនឹងប័ណ្ណមេឌីឃែ (Medicare Card)របស់អ្នកនឹងត្រូវបានគេរក្សា ការសម្ងាត់ (Confidential) ។

**បើអ្នកមានប័ណ្ណមេឌីឃែរ:**

- ចូរសួរវេជ្ជបណ្ឌិត មន្ទីរព្យាបាលឬអ្នកធ្វើការទាំងនោះថា តើគេមានផ្តល់ជូនអ្នក នូវ ប៊ូប៊ីលលីង (Bulkbilling) ឬទេមុននឹងជួបពិគ្រោះជាមួយគេ ។ ចូរយកប័ណ្ណមេឌីឃែទៅជាមួយអ្នកគ្រប់ពេលវេលាដែលអ្នកទៅឱ្យវេជ្ជបណ្ឌិត របស់អ្នកពិនិត្យ ទៅមន្ទីរព្យាបាល ឬទៅមន្ទីរពេទ្យ ។

**បើសិនជាអ្នកពុំមានប័ណ្ណមេឌីឃែទេនោះ**

មានកិច្ចបំរើខ្លះដូចជាមន្ទីរសុខភាពផ្នែកផ្លូវភេត នឹងផ្តល់ជូនអ្នកនូវកិច្ចបំរើដោយឥតគិតថ្លៃ ។ តែងតែសួរថា តើគេអាចផ្តល់នូវកិច្ចបំរើដោយឥតគិតថ្លៃឬទេ ។ បុគ្គលិកថែរក្សាសុខភាពតាមសហគមន៍ ឬបុគ្គលិកនៅឯមណ្ឌលផ្តល់កិច្ចបំរើដល់ជនអន្តោប្រវេសន៍ (Migrant Resource Centre) នឹងអាចឱ្យឱវាទថាតើអ្នកអាចដាក់ពាក្យសុំប័ណ្ណមេឌីឃែបានឬទេ ។

ដោយចុចនៅផ្នែកខាងលើនៃទំព័រនេះ អ្នកនឹងឃើញបញ្ជីនៃកិច្ចបំរើដែលអ្នកអាចឃើញពត៌មានអំពី HIV ហើយ និងកន្លែងដែល អ្នកអាចទៅយកពត៌មានទាំងនេះបាន ។ អ្នកអាចទូរស័ព្ទទៅកិច្ចបំរើទាំងនេះ ដើម្បីសួរអំពីកិច្ចបំរើដែលមាននៅតំបន់របស់អ្នក ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេប១នៃប្រភេទកិច្ចបំរើដែលអ្នកប្រហែលជាត្រូវប្រើភាគច្រើន ។

## 7.2 វេជ្ជបណ្ឌិតទូទៅ

ពេលនេះប្រហែលអ្នកបានទៅជួបពិគ្រោះជាមួយវេជ្ជបណ្ឌិតណាម្នាក់ជាទៀងទាត់ ឬមួយក៏ទៅជួបពិគ្រោះជាមួយវេជ្ជបណ្ឌិតណា ដែលកំពុងធ្វើការនៅមន្ទីរព្យាបាល ។
ប៉ុន្តែនៅពេលដែលអ្នកមានមេរោគ HIV ការស្វែងរកវេជ្ជបណ្ឌិតមួយ ដែលអ្នកពេញចិត្តគឺជាជំហានមួយដ៏ ចាំបាច់ក្នុងការរក្សាសុខភាពឱ្យល្អ ។ ចូរគិតអំពីកិច្ចបំរើសុខភាពទាំងឡាយ ដែលអ្នកប្រហែលជាត្រូវការរួចជ្រើសរើសយកវេជ្ជបណ្ឌិតឱ្យបានសមស្រប ។

**ចំណុចដែលអ្នកគួរយកមកគិតគឺ:**

- រកវេជ្ជបណ្ឌិតមួយដែលអ្នកស្រួលនិយាយជាមួយ និងទុកចិត្តហើយទៅជួបទៀងទាត់ដើម្បីពិនិត្យសុខភាព ។
- វេជ្ជបណ្ឌិតដែលមានតម្រិះវិជ្ជា និងការយល់ដឹងពីមេរោគ HIV និងជំងឺ AIDS ។
- វេជ្ជបណ្ឌិតដែលមានការដកពិសោធក្នុងការព្យាបាលអ្នកជំងឺ HIV ។
- វេជ្ជបណ្ឌិដែលមានសមត្ថភាពចេញសំបុត្រទិញថ្នាំ HIV ( ថ្នាំទាំងនេះត្រូវគេឱ្យឈ្មោះថា S100 ) ។មិនមែនវេជ្ជបណ្ឌិតណាក៏អាចចេញសំបុត្រទិញថ្នាំ S100 នេះបានទេ ។ បើសិនជាវេជ្ជបណ្ឌិតអ្នកមិនអាចចេញសំបុត្រទិញថ្នាំ S100 បានទេនោះ គាត់ **ប្រហែលជាអាច** បញ្ជូនអ្នកទៅវេជ្ជបណ្ឌិតដែលអាចចេញសំបុត្រទិញថ្នាំនេះ ។ ឬអ្នកក៏អាចទូរសព្ទ័ទៅក្រុមប្រឹក្សា អេដស៍ (AIDS Council) ក្នុងរដ្ឋ ឬដែនដីដែលអ្នកកំពុងរស់នៅ ឬទូរសព្ទ័ទៅសមាគមន៍វេជ្ជសាស្ត្រ HIV អូស្ត្រាលី (Australian Society For HIV Medicine) ដើម្បីពត៌មានបន្ថែម ។
- វេជ្ជបណ្ឌិតនោះនៅក្នុងតំបន់ដែលអ្នករស់នៅហើយអ្នកអាចទៅជួបដោយងាយស្រួល ។
- អ្នកទុកចិត្តការវិភាគ និងការព្យាបាលជំងឺរបស់វេជ្ជបណ្ឌិតនោះ ។

**វេជ្ជបណ្ឌិតរបស់អ្នកគួរជាមនុស្សដែលអាចះ**

- ផ្តល់ការពិនិត្យសុខភាពទូទៅ ។
- ឆ្លើយនូវសំណួរដែលអ្នកសួរហើយងាយស្រួលនឹងយល់ ។
- ជួយអ្នកក្នុងការតាមដានមើលការថែទាំសុខភាព និងចេញថ្នាំឱ្យអ្នកដើម្បីការពារកុំឱ្យកើតជំងឺផ្សេងៗ ។
- បញ្ជូនអ្នកទៅជួបអ្នកឯកទេស (Specialists) បើចាំបាច់ ។
- ធ្វើការណាត់ជួបឱ្យអ្នកទៅជួបជាមួយកិច្ចបំរើផ្សេងៗបើចាំបាច់ហើយចេញសំបុត្រទិញថ្នាំ S100 ដល់អ្នក ។

## 7.3 កិច្ចបំរើសុខភាពផ្លូវភេទ

មន្ទីរសុខភាពផ្លូវភេទទាំងនេះមិនត្រឹមតែផ្តល់កិច្ចបំរើផ្នែកពេទ្យដល់អ្នកទេ គេថែមទាំងផ្តល់ជូនអ្នកនូវកិច្ចបំរើ ផ្នែកផ្តល់ឱវាទគាំទ្រ និងពតិមានខាងផ្នែកផ្លូវភេទនិងបន្តពូជរួមបញ្ចូលទាំង HIV/AIDS ។

ការប្រើមន្ទីរពិនិត្យសុខភាពផ្លូវភេទអាចផ្តល់គុណប្រយោជន៍:

- បុគ្គលិកមានការដកពិសោធច្រើនជាមួយមនុស្សមានមេរោគ HIV/AIDS
- ភាគច្រើនបើកធ្វើការនៅពេលល្ងាច
- ភាគច្រើនមិនបង្ខំឱ្យអ្នកបង្ហាញអត្តសញ្ញាណប័ណ្ណប្រចាំខ្លួនឡើយ
- ភាគច្រើនផ្តល់នូវកិច្ចបំរើដោយឥតគិតថ្លៃ
- ភាគច្រើនមិនត្រូវការមេឌីឃែទេ ។

## 7.4 មន្ទីរពេទ្យ

ប្រហែលជាមានពេលខ្លះអ្នកត្រូវការទៅសំរាកនៅមន្ទីរពេទ្យ ។ ឧទាហរណ៏អ្នកប្រហែលជាមានកើតរោគដែលបណ្តាលមេរោគឆ្លៀត ឱកាសពេលដែលសុខភាពចុះខ្សោយហើយអ្នកត្រូវការការព្យាបាលជាពិសេស ។

មន្ទីរពេទ្យក៏អាចផ្តល់ផងដែរ នូវកិច្ចបំរើដែលទាក់ទងទៅនឹងផ្នែកHIV ដោយពុំចាំបាច់ឱ្យអ្នកស្នាក់នៅមន្ទីរពេទ្យឡើយ ។ កិច្ចបំរើរបស់ មន្ទីរពេទ្យទាំងនេះអាចជាការងាយស្រួលជាពិសេសបើអ្នកពុំមានកិច្ចបំរើជំនួយច្រើននៅតំបន់អ្នក ។មន្ទីរពេទ្យផ្តល់ កិច្ចបំរើដូចខាងក្រោម:

**កិច្ចបំរើសំរាប់អ្នកជំងឺនៅក្រៅមន្ទីរពេទ្យ (Outpatient Services)**

- ក្រុមអ្នកធ្វើការដែលមានការដកពិសោធន៏ផ្នែក HIV/AIDS ដូចជាវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា អ្នកផ្តល់យោបល់ អ្នកមើលការ ខុសត្រូវផ្នែកអាហារ ហើយនិងអ្នកបង្ហាត់ ឱ្យមានមុខវិជ្ជា ។
- គិលានុបដ្ឋាយិកាសមាគមន៏ ដែលអាចផ្តល់ការថែរក្សា ហើយនិងផ្តល់ជំនួយនៅក្នុងផ្ទះរបស់អ្នក ។
- កន្លែងទិញថ្នាំដែលអាចផ្តល់ថ្នាំ S100 ហើយនិងថ្នាំដ៏ទៃទៀត ។
- មន្ទីរបំរើ និងពិនិត្យរោគដែលអាចពិនិត្យរោគ ឬឱ្យថ្នាំក្នុងកំឡុងពេលមួយថ្ងៃ ។

**កិច្ចបំរើដល់អ្នកជំងឺក្នុងមន្ទីរពេទ្យ (In-patient Services)**

នៅពេលដែលអ្នកស្នាក់នៅក្នុងមន្ទីរពេទ្យមួយយប់ ឬក៏យូរជាងនេះ អ្នកនឹងត្រូវបានគេទទួលថា ជាអ្នកជំងឺក្នុងមន្ទីរពេទ្យ ។ ពេលខ្លះមន្ទីរពេទ្យអាចជាកន្លែងគួរឱ្យភ័យខ្លាច ។ អ្នកនឹងត្រូវគេសួរសំណួរធ្វើការពិនិត្យ ហើយតម្រូវឱ្យអ្នកចុះហត្ថលេខាផ្តល់ការអនុញ្ញាត ឱ្យគេ ក្នុងការពិនិត្យជំងឺ ។ ទាំងអស់នេះអាចធ្វើឱ្យអ្នកតានតឹងក្នុងចិត្ត ហើយពុំអាចទប់ទល់នឹងព្រឹត្តិការណ៏ជុំវិញខ្លួនអ្នក ជាពិសេសនៅពេល ដែលអ្នកមិនស្រួលខ្លួន ។ បើសិនជាអ្នកមិនអាចនិយាយឬក៏មិនយល់ភាសាអង់គ្លេសបានច្បាស់ទេ ជាការសំខាន់អ្នកត្រូវស្នើរកអ្នកបកប្រែ ភាសាម្នាក់នៅពេលគេផ្តល់ពតិមានអំពីសុខភាពថ្នាំ ឬក៏លទ្ធផលនៃការពិនិត្យរោគដល់អ្នក ។

បើសិនជាអ្នកមិនចេះអានក្រដាសស្នាម ដែល គេតម្រូវឱ្យអ្នកចុះហត្ថលេខាទេនោះ សូមរង់ចាំរហូតដល់មានអ្នកបកប្រែបកជូនអ្នក ។ ចូរកុំខ្លាចទាមទាររកអ្នកបកប្រែឬក៏ឱ្យគេពន្យល់អ្នកឱ្យដឹងច្បាស់ អំពីការពិនិត្យ ការព្យាបាល និងការថែរក្សាដែលអ្នកកំពុងទទួល ។ វាក៏ជាសិទ្ធិរបស់អ្នកក្នុងការយល់ដឹងសព្វគ្រប់អំពីការថែរក្សាសុខភាពរបស់អ្នក ។

មនុស្សភាគច្រើនមិនចូលចិត្តនៅមន្ទីរពេទ្យទេ ។ យ៉ាងណាមិញ អ្នកគួរទុកចិត្តថា ក្នុងកំឡុងពេលនេះ បុគ្គលិកពេទ្យជាច្រើនដែលបាន ហ្វឹកហ្វឺននឹងប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាពរបស់គេដើម្បីធ្វើឱ្យអ្នកស្រួលឡើងវិញ ។

ប្រហែលជាមានបុគ្គលិកមួយក្រុមតូចនឹងធ្វើការថែរក្សាអ្នក ។ រាប់បញ្ចូលទាំងវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកាអ្នកឱ្យយោបល់ និងអ្នកឯកទេសខាងផ្តល់ម្ហូបអាហារ ។ ចូរប្រើពេលវេលានេះដើម្បីសិក្សាឱ្យបានច្បាស់អំពីសុខភាពរបស់អ្នក ហើយនិងជាជំហានដែលអ្នកអាចប្រកាន់យកដើម្បីសេចក្តីសុខរបស់អ្នកទៅអនាគត ។

**មន្ទីរសង្គ្រោះបន្ទាន់ និងភាពអសន្ន (Emergency/Casualty Department)**

មនុស្សខ្លះចូលចិត្តទៅមន្ទីរសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យធំ នៅពេលដែលគេចង់ជួបវេជ្ជបណ្ឌិត ។ ជាការល្អអ្នកគួរធ្វើដូចនេះ នៅពេលណាដែលអ្នកត្រូវការឱ្យគេពិនិត្យជាបន្ទាន់យប់អាធ្រាត្រចុងសប្តាហ៍ ឬក៏ថ្ងៃឈប់សំរាក ហើយអ្នកមិនអាចទាក់ទងវេជ្ជបណ្ឌិតរបស់អ្នកបាន ។បើសិនជាអ្នកទៅមន្ទីរសង្គ្រោះបន្ទាន់ដោយសារបញ្ហាមិនជាបន្ទាន់ទេនោះអ្នកត្រូវរង់ចាំរយៈពេលយូរ មុននឹងអ្នកបានជួបវេជ្ជបណ្ឌិត ។ ទៅថ្ងៃមុខនៅពេលដែលអ្នកទៅមន្ទីរសង្គ្រោះបន្ទាន់ អ្នកនឹងមិនបានជួបវេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកាដដែលនោះទេ ។

## 7.5 កិច្ចបំរើមេរោគ ហេច អាយ វី និងជំងឺ អេដស៍ដទៃទៀត

អង្គការទាំងនេះផ្តោតទៅលើ HIV/AIDS ហើយផ្តល់នូវកិច្ចបំរើ ខុស១គ្នា ។ អង្គការទាំងនោះ មានក្រុមប្រឹក្សា HIV/AIDS (HIV/AIDS Council) អ្នករស់នៅជាមួយ HIV/AIDS ( People Living with HIV/AIDS) ផ្នែកព្យាបាលជំងឺ និង អង្គការផ្តល់ជំនួយសុខុមាលភាពផ្សេង១ទៀតដូចជាមូលនិធិ បប់ប៊ី ហ្គោលស្មីត ( Bobby Goldsmith Foundation) ជាដើម ។ ក្រុមប្រឹក្សា HIV/AIDS ផ្តល់ជូននូវ:

- ពត៌មានថ្មី១ អំពីជំងឺ HIV/AIDS និងការព្យាបាល
- ព្រឹត្តិប័ត្រផ្តល់ពត៌មាននិងសកម្មភាពសម្រាប់អ្នករស់នៅជាមួយមេរោគ HIV/AIDS
- សកម្មភាពជួបជុំគ្នាលេងសំរាប់រស់អ្នកនៅជាមួយមេរោគ HIV/AIDS
- ពត៌មានជុំវិញពិភពលោកអំពី HIV/AIDS ។

## 7.6 អ្នកផ្តល់យោបល់ និងឱវាទ សង្គមការី និងអ្នកចិត្តសាស្ត្រ

អ្នករស់នៅជាមួយមេរោគ HIV/AIDS អាចជាការពិបាក សូម្បីតែអ្នកមានមិត្ត ក្រុមគ្រួសារ និងដៃគូជួយគាំទ្រអ្នកក៏ដោយវានឹងមានរឿងខ្លះ១ដែលពួកគេប្រហែលជាមិនយល់ ។ កិច្ចបំរើ និងអង្គការជាច្រើនដូចជាក្រុមប្រឹក្សា AIDS មន្ទីរពេទ្យនិងមន្ទីរសុខភាពផ្លូវភេទមានអ្នកផ្តល់យោបល់ (counsellors) បុគ្គលិកបំរើសង្គម (social workers) និងអ្នកចិត្តវិជ្ជា (psychologists) ដែលអ្នកអាចពិគ្រោះជាមួយអំពី HIV ។

ការទៅជួបអ្នកផ្តល់យោបល់ បុគ្គលិកបំរើសង្គម ឬក៏អ្នកចិត្តវិជ្ជា ជាលើកដំបូង អ្នកមានការលំបាក ។ អ្នកអាចមានអារម្មណ៍ថា អ្នកមិនចង់

ឬមិនត្រូវការនិយាយជាមួយនរណាម្នាក់អំពីការមានមេរោគ HIV ទេ ឬក៏អ្នកគិតថាវាមិនសមនឹងនិយាយរឿងផ្ទាល់ខ្លួនជាមួយនឹងមនុស្សចំឡែកទាំងនេះឡើយ ។

ការជួបជាមួយនឹងអ្នកផ្តល់យោបល់បុគ្គលិកបំរើសង្គម ឬក៏អ្នកចិត្តវិជ្ជាគឺមិនមានន័យថា អ្នកពុំអាចនឹងដោះស្រាយនូវបញ្ហាអ្នកឡើយ ។

ផ្ទុយទៅវិញ ការផ្តល់យោបល់អាចផ្តល់ឱ្យ អ្នកនូវឱកាសដើម្បីនិយាយអំពីអារម្មណ៍របស់អ្នក ហើយនិងរកចម្លើយដើម្បីទប់ទល់នឹងបញ្ហា ផ្សេងៗ ក្នុងការរស់នៅជាមួយ HIV/AIDS ។ អ្នកផ្តល់យោបល់ បុគ្គលិកបំរើសង្គម និងអ្នកចិត្តវិជ្ជា នឹងមិនវិនិឆ្ឆ័យឬ ស្តីបន្ទោសអ្នក

ពីព្រោះអ្នកមានមេរោគ HIV ប្រុសស្រឡាញ់ប្រុស ស្ត្រីស្រឡាញ់ស្ត្រី ឬក៏មនុស្សប្រើថ្នាំ ញៀនឡើយ ។ ពួកគេទាំងនេះ ប្រហែល ជាឱ្យយោបល់ដល់អ្នក ប៉ុន្តែគេតែងតែគាំទ្រនូវការសម្រេចចិត្តរបស់អ្នក ។

**អ្នកឱ្យផ្តល់ឱវាទ (យោបល់) ឬបុគ្គលិកបំរើសង្គមរបស់អ្នក**

- ជួយអ្នករកកិច្ចបំរើសមរម្យសំរាប់អ្នក
- ជួយក្នុងការលើកទឹកចិត្ត
- ជួយអ្នកក្នុងការសម្រេចចិត្តថាតើត្រូវប្រាប់នរណា ឬប្រាប់គេរបៀបណា ហើយព្រមទាំងនៅជាមួយអ្នកនៅពេលដែលអ្នក ប្រាប់គេ ។
- ទៅជាមួយអ្នកក្នុងការណាត់ជួបខ្លះ
- ពន្យល់ប្រាប់អ្នកនូវអ្វីដែលអ្នកមិនយល់ ។

វាគឺជាការសម្រេចចិត្តរបស់អ្នកថា តើអ្នកចង់បានការផ្តល់យោបល់ ឬក៏អត់ ។ មនុស្សខ្លះធ្វើការណាត់ជួបជាមួយអ្នកផ្តល់យោបល់ និងបុគ្គលិកបំរើសង្គមជាទៀងទាត់អ្នកខ្លះទៀតជ្រើសរើសអ្នកផ្តល់យោបល់នៅពេលណាដែលមានបញ្ហា ឬពេលត្រូវការគាំទ្របន្ថែម ។

*វេជ្ជបណ្ឌិតបានប្រាប់ខ្ញុំថា ខ្ញុំមានមេរោគ HIV គាត់ពុំបានដឹងណាស់ណាទេអំពី HIV ។ គាត់និយាយ ហើយនិយាយទៀតថា គឺមានកន្លែងដែលខ្ញុំអាចទៅរកការគាំទ្រព្រោះគាត់ពុំអាចជួយខ្ញុំបានទេ ។ ខ្ញុំបានទៅផ្ទះវិញ ហើយពុំបានព្យាយាមរកជំនួយអ្វីទេ ។ តាមពិតខ្ញុំមិនជឿថាមានកន្លែងផ្តល់ជំនួយឯណាទេ ។ ខ្ញុំគិតក្នុងចិត្តថា ខ្ញុំនឹងត្រូវស្លាប់ក្នុងពេលឆាប់ៗនេះជាមិនខាន ព្រោះគ្មាននរណាម្នាក់អាចជួយខ្ញុំបានឡើយ ។ បន្ទាប់មកខ្ញុំមានជំងឺក្លាយកើតឡើង បណ្តាលឱ្យធ្លាក់ខ្លួនឈឺចូលដេកនៅមន្ទីរពេទ្យ ។ បុគ្គលិកធ្វើការ បំរើសង្គមបានមកជួបនឹងខ្ញុំ ហើយខ្ញុំបាននិយាយអំពីការភ័យខ្លាចរបស់ខ្ញុំ និងរបៀបរស់នៅនៃជីវិតខ្ញុំប្រាប់គាត់ ។ ខ្ញុំបានជួបជាមួយបុគ្គលិកបំរើសង្គមអស់រយៈពេលពីរឆ្នាំមកហើយ ។ ខ្ញុំនៅតែនិយាយពីការភ័យខ្លាចរបស់ខ្ញុំ អំពីជំងឺ និងការស្លាប់របស់ខ្ញុំប្រាប់គាត់ ប៉ុន្តែខ្ញុំក៏បាននិយាយអំពីរឿងដ៏ល្អក្នុងជីវិតរបស់ខ្ញុំប្រាប់គាត់ដែរ ។ វាជាជំនួយដល់ខ្ញុំច្រើនណាស់ ពេលខ្លះខ្ញុំនៅតែមានអារម្មណ៍ថា ខ្ញុំកំពុងដើរលើផ្លូវដែលខ្ញុំមិនស្គាល់ ប៉ុន្តែខ្ញុំគិតថាយើងទាំងអស់គ្នាគឺសុទ្ធតែអញ្ចឹង ។*

## 7.7 របៀបប្រើកិច្ចបំរើដែលអ្នកត្រូវការ

- សំរាប់ពតិមានទូទៅអំពីប្រពន្ធ័សុខាភិបាល សូមនិយាយទៅនរណាម្នាក់ដែលមានការដឹងយល់ច្រើនពីផ្នែកនេះ ។ វេជ្ជបណ្ឌិតរបស់អ្នក ឬអ្នកធ្វើការផ្នែកសុខភាពសហគមន៍អាចជួយអ្នកបាន ។
- សួរវេជ្ជបណ្ឌិតរបស់អ្នកពីពតិមានអំពីកិច្ចបំរើទាក់ទងនិង HIV/AIDS ។
- បើសិនជាអ្នកមិនចេះនិយាយឬពុំយល់ភាសាអង់គ្លេសបានល្អទេនោះសូមប្រើអ្នកបកប្រែ ។ ធ្វើរបៀបនេះអាច ទទួលប្រយោជន៍ច្រើនអំពីកិច្ចបំរើ ។ ប្រើអ្នកឯកទេសផ្នែកបកប្រែ កុំអនុញ្ញាតឱ្យមិត្តភក្តិ ឬសាច់ញាតិបកប្រែជូនអ្នកឡើយ ។
- អ្នកត្រូវសួរថា តើអ្នកត្រូវបង់លុយសំរាប់កិច្ចបំរើទាំងនេះ ឬកិច្ចបំរើទាំងនេះត្រូវបានរដ្ឋជួយឧបត្ថម្ភទាំងស្រុង ឬទេ? ។

- បើសិនជាអ្នកមិនប្រាកដថាអង្គការទាំងនោះផ្តល់កិច្ចបំរើអ្វីខ្លះទេ នោះចូរសួរពួកគេ ឬក៏ទៅមើលថាតើនេះជាកិច្ចបំរើ ដែលអ្នកត្រូវការប្រាកដមែនទេ?
- បើសិនអ្នកមានលទ្ធភាព ចូរសួរអ្នកដែលមានមេរោគ HIV/AIDS អំពីកិច្ចបំរើដែលពួកគេគិតថាមានប្រយោជន៍ ។
- របៀបដែលប្រើប្រាស់ កិច្ចបំរើគឺជាការសម្រេចចិត្តរបស់អ្នក ។ អ្នកប្រហែលជារកឃើញអង្គការដែលផ្តល់ កិច្ចបំរើគ្រប់បែបយ៉ាងដែលអ្នកត្រូវការក្នុងពេល បច្ចុប្បន្នអ្នកអាចប្រើនូវកិច្ចបំរើខុសៗគ្នាសំរាប់បញ្ហាខុសៗគ្នា ។
- ពេលខ្លះវាគឺជាការពិបាកក្នុងការរកកិច្ចបំរើឱ្យត្រូវនឹងសេចក្តីត្រូវការរបស់អ្នក ។ អ្នកប្រហែលជាជួបប្រទះក្នុងការយឺតយ៉ាវឬទទួល ពតិមានដែលផ្ទុយពីគ្នា ហើយអ្នកត្រូវទៅកន្លែងខុសៗគ្នាជាច្រើនដើម្បីរកពតិមានអំពីកិច្ចបំរើដែលអ្នកត្រូវការ ។ វាជាការសំខាន់ដែល អ្នកកុំឈប់ការព្យាយាមនេះ បើសិនជាអ្នកមិនពេញចិត្តចំពោះកិច្ចបំរើណាមួយ អ្នកអាចរកកិច្ចបំរើផ្សេងទៀតដែលស្របទៅតាមសេចក្តីត្រូវការរបស់អ្នក ។

*លើកដំបូងដែលខ្ញុំបាននិយាយជាមួយនឹងអ្នកផ្តល់យោបល់ គឺនៅពេលដែលខ្ញុំដឹងថា ខ្ញុំមានមេរោគ HIV ។ គាត់ប្រាកដជាចង់ជួយខ្ញុំណាស់ប៉ុន្តែនៅពេលនោះ ខ្ញុំពុំបានគិតច្បាស់ ។ អស់រយៈពេលមួយឆ្នាំ ទើបខ្ញុំអាចនិយាយទៅកាន់គេ ហើយនិងប្រាប់បងប្អូនស្រីខ្ញុំ ។ បងប្អូនស្រីខ្ញុំមករស់នៅប្រទេសអូស្ត្រាលីយូរជាងខ្ញុំ ហើយគាត់បាននាំខ្ញុំទៅមន្ទីរពេទ្យ នៅទីនោះ ខ្ញុំបានធ្វើ ការពិនិត្យរោគ ។ ឥឡូវខ្ញុំបានទៅទីនោះជាទៀងទាត់ ។ ពួកគេថែរក្សាសុខភាពខ្ញុំ ហើយឱ្យពតិមានជាច្រើនអំពី HIV/AIDS ខ្ញុំនៅតែមានអារម្មណ៍ភ័យខ្លាចអំពីអនាគតរបស់ខ្ញុំប៉ុន្តែខ្ញុំក៏កំពុងសប្បាយជាមួយជីវិតខ្ញុំដែរ ។*

## 7.8 អ្នកបកប្រែ

ការស្វែងរកកិច្ចបំរើផ្នែកថែរក្សាសុខភាពដោយប្រើថ្នាំពេទ្យ និងពតិមានអាចជាការពិបាក បើសិនអ្នកមិនចេះនិយាយភាសាអង់គ្លេស ។ យ៉ាងណាមិញ អ្នកអាចប្រើអ្នកបកប្រែ (interpreter) នៅពេលដែលអ្នកនិយាយជាមួយបុគ្គលិកថែរក្សាសុខភាព ឬ កិច្ចបំរើផ្សេងៗ ។ កិច្ចការរបស់អ្នកបកប្រែ គឺបកប្រែនូវអ្វីដែលអ្នក និងបុគ្គលិកសេវាកម្មនិយាយគ្នាទៅវិញទៅមក ។ អ្នកបកប្រែមិនចូលរួមក្នុងការពិភាក្សាអ្វីទៀតឡើយ ។

ដោយប្រើអ្នកបកប្រែភាសាអ្នកអាចៈ

- យល់នូវអ្វីទាំងអស់ដែលគេប្រាប់អ្នក
- ដឹងប្រាកដថា អ្វីដែលអ្នកនិយាយ គេនឹងយល់
- សួរសំណួរហើយនិងបានចម្លើយ
- បានដឹងច្បាស់លាស់ក្នុងការឱ្យសិទ្ធិគេធ្វើការពិនិត្យនិងព្យាបាលជំងឺ ។

មានមនុស្សជាច្រើនមិនចង់ប្រើអ្នកបកប្រែទេ ជាពិសេសទាក់ទងទៅនឹងផ្នែកសុខភាព ។ អ្នកប្រហែលជាព្រួយបារម្ភថាអ្នកបកប្រែជាមនុស្សដែលអ្នកស្គាល់នៅក្នុងសហគមន៍របស់អ្នក ឬមួយជាមិត្តភក្តិដែលមិនដឹងថាអ្នកមានមេរោគ HIV ។ ដូចគ្នានឹងអ្នកមានវិជ្ជាជីវៈខាងថែរក្សាផ្នែកសុខភាពដែរ អ្នកបកប្រែត្រូវតែថែរក្សាការសម្ងាត់របស់អ្នកមានអ្នកបកប្រែតាមទូរស័ព្ទគ្រប់ទីកន្លែងក្នុងប្រទេសអូស្ត្រាលី ។ មានផ្តល់កិច្ចបំរើតាមទូរស័ព្ទទាក់ទងរវាងអ្នក បុគ្គលិកកិច្ចបំរើ និងអ្នកបកប្រែ ។

ចូរជៀសវាងប្រើមនុស្សណាដែរគ្មានសញ្ញាប័ត្រ គេប្រហែលជាមិនដឹងថាការរក្សាការសម្ងាត់របស់អ្នក ជាការសំខាន់នោះឡើយ ហើយប្រហែលជាមិនមានការហ្វឹកហ្វឺន ផ្នែកបកប្រែពតិមាន( ជាពិសេសពតិមានផ្នែកសុខភាព ឱ្យបានត្រឹមត្រូវទេ ។ អ្នកអាចមានមិត្តភក្តិដែល

អ្នកទុកចិត្ត ឬក៏សាច់ញាតិមកជាមួយនៅពេលដែលអ្នកធ្វើការណាត់ជួបជាមួយបុគ្គលិកសុខភាព និងជាមួយអ្នកបកប្រែបើសិនជា អ្នកចូលចិត្ត ។ ពួកគេអាចធ្វើការណាត់ជួបជាមួយអ្នកហើយរកអ្នកបកប្រែជូនអ្នក ។ យ៉ាងណាក៏ដោយមិត្តភក្តិ និងសាច់ញាតិមិនគួរបកប្រែជូនអ្នកឡើយ ។

**កិច្ចបំរើបកប្រែភាសា សរសេរ និងនិយាយ (Translating and Interpreting Service) TIS**

ពេលអ្នកទូរសព្ទ័មក TIS អ្នកធ្វើការជួយភ្ជាប់ទូរសព្ទ័អ្នកទៅបុគ្គលិកសុខភាព និងអ្នកបប្រែតាមទូរសព្ទ័អ្នកបកប្រែនឹងជួយធ្វើឱ្យអ្នក និងអ្នកដែលផ្តល់កិច្ចបំរើ អាចនិយាយស្តាប់គ្នាទៅវិញទៅមក ហើយធ្វើឱ្យអ្នកយល់នូវចម្លើយនៃសំណួរទាំងអស់ដែលអ្នកសួរទៅគេបាន ។

TIS រក្សាភាពសម្ងាត់យ៉ាងហ្មត់ចត់ អ្នកបកប្រែនៅ TIS មិនដឹងអំពីតើអ្នកជានរណា ឬតើអ្នកទូរសព្ទ័មកពីណាទេ ។

**TIS ធ្វើការ ២៤ ម៉ោងក្នុង ១ថ្ងៃ ៧ ថ្ងៃក្នុងមួយសប្តាហ៏ ។ លេខទូរសព្ទ័ TIS គឺ 13 14 50**

អ្នកអាចទូរសព្ទ័ពីគ្រប់តទីកន្លែងក្នុងប្រទេសអូស្ត្រាលី ។ អ្នកផ្តល់កិច្ចបំរើ អាចទាក់ទង TIS ជូនអ្នក ឬអ្នកអាចទូរសព្ទ័ដោយខ្លួនឯងក៏បាន ។